**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Mar-2013, 16:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : **សាធារណៈ/Public**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ ខៀវ សំផន ទៅនឹងភាពអាចទទួលយកបាននៃឯកសារថ្មីៗ**

---

<u>ដាក់ដោយ៖</u>

**សហព្រះរាជអាជ្ញា:**
ជា លាង
Andrew CAYLEY

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រមJean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

<u>ចម្លងជូន៖</u>

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តី:**
សុន អរុណ
Michiel PESTMAN
Victor KOPPE
គង់ សំអុន
Anta GUISSÉ

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU FORT

Arthur VERCKEN
Jacques VERGÈS

## I. សេចក្ដីផ្ដើម

1. មេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការពារក្ដី") បានដាក់សេចក្ដីជំទាស់បន្ថែម[1] ("សេចក្ដីជំទាស់") ទៅនឹងឯកសារ "ថ្មី" ដែលត្រូវបានដាក់សម្រាប់ការទទួលយកជាផ្នែកមួយនៃបញ្ជីឯកសារដែលត្រូវបានស្នើសុំចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ របស់សហព្រះរាជអាជ្ញា ("បញ្ជីកែសម្រួល ")[2]។ មេធាវីការពារក្ដីអះអាងថាពួកគាត់ពុំទាន់មានឱកាសមុនៗ ដើម្បីជំទាស់ទៅនឹងឯកសារទាំងនេះឡើយ ហើយមិនអាចមើលឯកសារខ្លះបាន។ សេចក្ដីជំទាស់ត្រូវបានជូនដំណឹងទៅភាគីកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣។

2. សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបតាមរយៈនេះ។ សហព្រះរាជអាជ្ញាសូមអះអាងថា មេធាវីការពារក្ដីមានឱកាស ដើម្បីជំទាស់ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរទៅនឹងឯកសារ "ថ្មី" ដែលមាននៅក្នុងបញ្ជីកែសម្រួល ក្នុងអំឡុងកិច្ចពិភាក្សា និងការលើកសេចក្ដីសន្និដ្ឋានស្ដីពីបញ្ជីកែសម្រួលទាំងនោះ ហើយពួកគាត់បានពិនិត្យមើលឯកសារទាំងនោះតាមរយៈឃ្លាំងផ្ទុកឯកសាររួមយ៉ាងហោចណាស់ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១១ មកម្ល៉េះ។ ដូច្នេះ មិនមានហេតុផលជំទាស់បន្ថែមទៀតទេ ក្នុងដំណាក់កាលនេះ។

3. និយាយម្យ៉ាងទៀត ចំពោះសេចក្ដីជំទាស់សំខាន់ៗដែលមេធាវីការពារក្ដីបានលើក សហព្រះរាជអាជ្ញាសូមអះអាងថាមានតែសេចក្ដីជំទាស់ចំនួន ១២ ប៉ុណ្ណោះ ដែលត្រូវបានមេធាវីការពារក្ដីលើកឡើងប្រកបដោយប្រសិទ្ធភាព ពាក់ព័ន្ធនឹងឯកសារនានាដែលអាចរងការជំទាស់។ សហព្រះរាជអាជ្ញាបានឆ្លើយតបនៅក្នុងឧបសម្ព័ន្ធភ្ជាប់ពាក់ព័ន្ធនឹងឯកសារទាំង ១២ នោះ។

[1] ឯកសារ **E246/1/1** សេចក្ដីជំទាស់របស់ខៀវ សំផន មិនទទួលយកឯកសារថ្មី, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ជូនដំណឹងកាលពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣។

[2] ឯកសារ **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្ដី, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (និងឧបសម្ព័ន្ធចំនួន ២០ ដែលទាក់ទង)។

## II. ប្រវត្តិនីតិវិធី

4. កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា តបទៅនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង[3] បានដាក់បញ្ជីមួយនៅក្នុងទម្រង់ជាតារាងឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង និងឯកសារថ្មីៗដែលខ្លួនបានមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ("បញ្ជីបឋម")។ បញ្ជីនេះត្រូវបានបែងចែកជាឧបសម្ព័ន្ធចំនួន ២០ ទៅតាមប្រភេទនៃឯកសារ។ ឧបសម្ព័ន្ធទី ២១ ក៏ត្រូវបានផ្តល់ផងដែរ ដែលគ្រាន់តែបានចងក្រងឯកសារ "ថ្មី" ទាំងអស់នេះ *ដូចជា* ឯកសារដែលពុំទាន់មានក្នុងសំណុំរឿង ដែលត្រូវបានចែកចាយនៅក្នុងឧបសម្ព័ន្ធផ្សេងៗ[4]។

5. បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យភាគីដាក់បញ្ជីឯកសារដែលទាក់ទងតែទៅនឹងសវនាការដំណាក់កាលទី១[5]។ សហព្រះរាជអាជ្ញាបានដាក់ជាថ្មីនូវបញ្ជីបឋមរបស់ខ្លួន ដោយហាយឡាយ ពណ៌បែតងនូវឯកសារទាំងឡាយនៅក្នុងឧបសម្ព័ន្ធនីមួយៗនៃឧបសម្ព័ន្ធទាំង២០ ដែលទាក់ទងនឹងសវនាការនៅដំណាក់កាលទី១ ("បញ្ជីកែសម្រួល")[6]។ ឯកសារ "ថ្មី" ត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីកែសម្រួល។ សហព្រះរាជអាជ្ញាពុំបានដាក់ជាថ្មីនូវឧបសម្ព័ន្ធ ២១ ជាមួយបញ្ជីកែសម្រួលទាំងនេះឡើយ។

6. កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់បញ្ជី ដោយបញ្ជាក់អំពីឯកសារនានាពីបញ្ជីដំណាក់កាលដំបូង ដែលភាគីបានចាត់ទុកថាពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលត្រូវកោះហៅនៅក្នុងអំឡុងពេលពាសប្តាហ៍ដំបូង (ដំណាក់កាលទី១) នៃសវនាការ និងដាក់

---

[3] ឯកសារ **E9** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ១២(i)-(ii)។

[4] ឯកសារ **E9/31** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការស្របតាមវិធាន ៨០(៣) (ជាមួយឧបសម្ព័ន្ធ ២១) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១។

[5] ឯកសារ **E1/4.1** ប្រតិចារឹកនៃសវនាការបឋម, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ ២៥។

[6] ឯកសារ **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (និងឧបសម្ព័ន្ធចំនួន ២០ ដែលទាក់ទង)។

សេចក្តីជំទាស់នានានៅក្នុងអំឡុងរយៈពេលចំនួន ១០ ថ្ងៃនៃការដាក់ឯកសារទាំងនោះ[7]។ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានប្រគល់បញ្ជីឯកសាររបស់ខ្លួនទាក់ទងនឹងសវនាការរយៈពេល ៣ សប្តាហ៍ដំបូង[8]។ សហព្រះរាជអាជ្ញាបានដាក់ឯកសារចំនួន ៩៧៨ រួមទាំងឯកសារនានាដែលពុំទាន់មានក្នុងសំណុំរឿង[9]។ ក្រុមមេធាវីការពារក្តីបានដាក់សេចក្តីជំទាស់ទូទៅទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញា[10]។ ពិសេស មេធាវីការពារក្តីបានដាក់សេចក្តីជំទាស់ទៅតាមប្រភេទនៃឯកសារ រួមទាំងសេចក្តីជំទាស់ទៅនឹង "ឯកសារថ្មីដែលពុំមានក្នុងសំណុំរឿង និងពុំទាន់បង្ហាញទៅភាគីដទៃ"[11]។ បន្ទាប់មកទៀត នៅក្នុងសេចក្តីជំទាស់របស់ពួកគាត់ មានភាពច្បាស់លាស់ដែលថាមេធាវីការពារក្តី ពុំបានជំទាស់ទៅនឹងឯកសារទាំងនោះឡើយ ដោយហេតុថាឯកសារទាំងនោះជាឯកសារ "ថ្មី" ឡើយ ប៉ុន្តែដោយហេតុថាពួកគាត់បានអះអាងថាពួកគាត់ពុំអាចពិនិត្យមើលឯកសារទាំងនោះ បានដោយបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង "បដិសេធឯកសារទាំងអស់ដែលមេធាវីការពារក្តីពុំមានលទ្ធភាពអាចពិនិត្យមើលបាន"[12]។ សហព្រះរាជអាជ្ញាបានឆ្លើយ ដោយបានជូនដំណឹងទៅក្រុមមេធាវីការពារក្តី និងពិសេស គឺមេធាវីការពារក្តី ខៀវ សំផន ថាឯកសារទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណថា

[7] ឯកសារ **E131/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង៖ បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, ទំព័រ ១។

[8] ឯកសារ **E131/1/4** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅក្នុងអំឡុងពេល៣ សប្តាហ៍ដំបូងនៃសវនាការ ជាមួយនឹងឧបសម្ព័ន្ធកសម្ងាត់, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ **E131/1/4.1** ឧបសម្ព័ន្ធ ក។

[9] ឯកសារ **E131/19** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នឹងបញ្ជីឯកសារសម្រាប់សវនាការវគ្គដំបូង, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ៦ (យោងឯកសារ E131/1/4 ត្រង់ជើងទំព័រ ៩ (ដែលកំណត់អត្តសញ្ញាណឯកសារថ្មី))។

[10] ឯកសារ **E114** ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១។ ឯកសារ **E131/6** សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង,ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ឯកសារ **E131/1/9** ការជំទាស់ ការកត់សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[11] ឯកសារ **E131/6** សេចក្តីជំទាស់របស់ ខៀវ សំផន, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, កថាខណ្ឌ ៤១។

[12] ឯកសារ **E131/6** សេចក្តីជំទាស់របស់ ខៀវ សំផន, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, កថាខណ្ឌ ៤៨។

ជាឯកសារ “ថ្មី” ភាគីអាចចូលមើលបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងសំណុំឯកសារឈ្មោះថា “ឯកសារថ្មីរបស់ ក.ស.ព សម្រាប់សំណុំរឿង ០០២”[13]។

7. នៅក្នុងអនុស្សរណៈថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ ដដែលនោះដែរ អង្គជំនុំជម្រះសាលាដំបូងក៏បានបង្គាប់ឲ្យភាគីចង្អុលបង្ហាញថា តើពួកគេជំទាស់ទៅនឹងឯកសារនានាដែលត្រូវជំនុំជម្រះដំណាក់កាលដំបូងនៅសេសសល់ ដែលភាគីបានស្នើ ឬទេ រួមទាំងបញ្ជីដែលត្រូវបានកែប្រែផង ត្រឹមថ្ងៃទី៥ ខែមករា ឆ្នាំ២០១២[14]។ មេធាវីការពារក្តីបានដាក់សារណាជំទាស់ទៅនឹងឯកសារដែលនៅសេសសល់ក្នុងបញ្ជីកែប្រែរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២[15]។ មេធាវីការពារក្តីត្រឹមតែលើកឡើងសាជាថ្មីនូវការជំទាស់របស់ខ្លួនពីមុនៗ ចំពោះឯកសារនានាទៅតាមប្រភេទនីមួយៗ រួមទាំងការជំទាស់ទៅនឹងឯកសារ “ថ្មីៗ” ផងដែរ[16]។

8. នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបំភ្លឺថា មានតែឯកសារដែលមិនបានបញ្ចូលក្នុងបញ្ជី ខែមេសា ឆ្នាំ២០១១ របស់ភាគី (រួមទាំងបញ្ជីដើមរបស់សហព្រះរាជអាជ្ញាដែរ) ដែលនឹងត្រូវចាត់ទុកថា ឯកសារ “ថ្មី” សម្រាប់គោលបំណងដែលតម្រូវឲ្យស្របតាមវិធាន ៨៧(៤)[17]។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការលើកជាទឡ្ហីករណ៍ផ្ទាល់មាត់ ស្តីពីភាពទទួលយកបាននៃឧបសម្ព័ន្ធ ១ ដល់ ៥ នៃបញ្ជីកែប្រែពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២[18]។ បន្ទាប់មក អង្គជំនុំជម្រះបានធ្វើជាបញ្ជីនូវឧបសម្ព័ន្ធនានាដែលខ្លួនបានរៀបចំដាក់នៅចំពោះមុខ (ក១ ដល់ ក១០) និង

---

13 ឯកសារ **E131/19** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នឹងបញ្ជីឯកសារសម្រាប់សវនាការវគ្គដំបូង, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ៥១។

14 អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E131/1** ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ២ ។

15 ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូងឯកសារ **E131/1/10**, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២; សេចក្តីជំទាស់របស់លោក ខៀវ សំផន មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងៗទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន ឯកសារ **E131/1/11**, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២; ការជំទាស់របស់ លោក នួន ជា ទៅនឹងឯកសារ និងសារណាបន្ថែមដោយអនុលោមតាមវិធាន ៩២ ឯកសារ **E131/1/12** ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២។

16 សេចក្តីជំទាស់របស់លោក ខៀវ សំផន ឯកសារ **E131/1/11** ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៥។

17 អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្រោមកម្មវត្ថុ “ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២)” ឯកសារ **E159** ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ១។

18 អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E159** ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៥។

បានថ្លែងថា "ឯកសារទាំងអស់" នៅក្នុងឧបសម្ព័ន្ធទាំងនេះនឹងត្រូវយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបានផ្តល់នូវចំនួនឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនីមួយៗ[19]។ ចំនួនឯកសារដែលអង្គជំនុំជម្រះផ្តល់ឱ្យសម្រាប់ឧបសម្ព័ន្ធនីមួយៗគឺជាចំនួនសរុបនៃឯកសារដែលមានក្នុងឧបសម្ព័ន្ធនោះរួមទាំងឯកសារ "ថ្មីៗ" ផងដែរ[20]។

9. ពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានរៀបចំសវនាការស្តីពីភាពទទួលយកបាននៃឯកសារនានានៅក្នុងឧបសម្ព័ន្ធ ក១ ដល់ ក៥ ចំពោះឯកសារដែលមានការជំទាស់[21]។ ក្នុងអំឡុងពេលសវនាការប៉ុន្មានថ្ងៃនោះ ក្រុមមេធាវីការពារក្តីទាំងអស់បានជំទាស់ទៅនឹងឯកសារនានានៅក្នុងឧបសម្ព័ន្ធដែលពាក់ព័ន្ធ ហើយពុំមានក្រុមមេធាវីការពារក្តីណាមួយទាមទារថាឯកសារ "ថ្មីៗ" គួរត្រូវដកចេញពីការជំទាស់របស់ពួកគេទេ[22]។ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានស្នើដោយផ្ទាល់មាត់មួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សុំឱ្យបញ្ចូលឯកសារទាំងអស់ដែលមានក្នុងបញ្ជីកែប្រែរបស់ខ្លួនទៅក្នុងឧបសម្ព័ន្ធ ក១ ដល់ ក៥[23]។

10. នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា "អនុលោមតាមវិធាន ៨៧(៣)" អង្គជំនុំជម្រះនឹងចាប់ផ្តើមពិភាក្សាទៅលើ "ឯកសារទាំងឡាយដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលមកទល់នឹងពេលនេះពុំទាន់ត្រូវបានយកទៅពិភាក្សានៅ

---

[19] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E159** ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៨។

[20] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E159** ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៨។

[21] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/27.1** ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២; ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/28.1** ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២; ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/29.1**, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២។

[22] សូមមើល ឧទាហរណ៍, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/28.1** ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៦៣ ដល់ ៧១, ទំព័រ ១១១ ដល់ ១១៧ (ភាសាអង់គ្លេស); ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/29.1** ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៤៩ ដល់ ៥៤ (ភាសាអង់គ្លេស); ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/30.1** ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៣៦ ដល់ ៣៧, ទំព័រ ១០៦ ដល់ ១១២ ។

[23] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/30.1** ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៦៨។

ឡើយ”[24]។ អង្គជំនុំជម្រះបានថ្លែងបន្ថែមទៀតថា “ហេតុនេះ សវនាការលើឯកសារនេះគឺជាការបញ្ចប់នូវការដេញដោលទៅលើឯកសារទាំងឡាយដែលបានស្នើឡើងដោយភាគីនានា នៅក្នុងសំណុំរឿង ០០២/០១”[25]។

11. នៅក្នុងអនុស្សរណៈចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា សវនាការនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ ខាងមុខ អង្គជំនុំជម្រះនឹង “បែងចែកពេលវេលាសម្រាប់ការជំទាស់ដោយផ្ទាល់មាត់ទៅលើឯកសារទាំងឡាយ ដែលភាគីបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ ដែលឯកសារទាំងនោះពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២/០១ (ឯកសារ E109/1.1, E109/2.1, E109/4, E109/6.2) និងដែលពុំទាន់បានលើកយកមកពិភាក្សានៅក្នុងសវនាការមកទល់ពេលបច្ចុប្បន្ន។ សវនាការផ្ទាល់មាត់ទាំងនេះធ្វើឡើងជំនួសឲ្យការដាក់សារណាជាលាយលក្ខណ៍អក្សរ”[26]។ ឯកសារ E109/4 និងឧបសម្ព័ន្ធរបស់វាដែលពាក់ព័ន្ធគឺជាបញ្ជីកែប្រែ ដែលរួមមានឯកសារ “ថ្មីៗ”។

12. បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីឯកសារដែលត្រូវលើកឡើង នៅក្នុងសវនាការ ដោយបញ្ជាក់ឲ្យបានច្បាស់ថា អង្គជំនុំជម្រះមានបំណងបើកសវនាការដើម្បីដោះស្រាយបណ្ដាឯកសារទាំងអស់ដែលនៅសេសសល់ពីបញ្ជីកែប្រែ (លើកលែងតែឧបសម្ព័ន្ធ ១២ និង ១៣)[27] ដោយអះអាងថា សវនាការនោះនឹងពាក់ព័ន្ធទៅនឹង “ប្រភេទឯកសារទាំងអស់ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់មកអង្គជំនុំជម្រះ ប៉ុន្តែពុំទាន់ត្រូវបានបង្ហាញក្នុងអំឡុងសវនាការលើឯកសារកាលពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៩ ខែមករា និង ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ កន្លងមក មានជាអាទិ៍ ...”[28]—និងបានដំណើរការបញ្ចូលក្នុងបញ្ជីនូវឧបសម្ព័ន្ធ ៦ ដល់ ១១ និង ១៤ ដល់ ២០។ ជាថ្មីម្ដងទៀត សម្រាប់ឧបសម្ព័ន្ធមួយៗនៃឧបសម្ព័ន្ធទាំងនេះ ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ឲ្យស្មើនឹងចំនួនឯកសារសរុបនៅក្នុងឧបសម្ព័ន្ធ រួមទាំងឯកសារ “ថ្មីៗ” ទាំងអស់ ហើយអង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា

---

[24] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្រោមកម្មវត្ថុ “សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១” ឯកសារ **E172** ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ទំព័រ ១។

[25] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E172** ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ទំព័រ ១ ។

[26] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្រោមកម្មវត្ថុ “សវនាការផ្ទាល់មាត់បន្ថែមលើឯកសារ (ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១២” ឯកសារ **E172/1** ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១។

[27] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E172/1** ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កំណត់សម្គាល់ ១។

[28] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E172/1** កថាខណ្ឌ ២។

"ឯកសារទាំងអស់" នៅក្នុងឧបសម្ព័ន្ធនីមួយៗនឹងត្រូវយកមកពិចារណាសម្រេច[29]។ អង្គជំនុំជម្រះសាលាដំបូងក៏បានជូនដំណឹងផងដែរថា "សេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងការពិភាក្សាអំពីឯកសារថ្មីៗទាំងឡាយដែលភាគីបានបង្ហាញនៅពេលណាមួយសមស្រប បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះ"[30]។ បន្ទាប់ពីបានទទួលព័ត៌មានបន្ថែមពីភាគីរួច អង្គជំនុំជម្រះសាលាដំបូងបានចេញសំណៅកែប្រែមួយនៃអនុស្សរណៈនេះនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១២[31] ដែលលើកឡើងជាថ្មីនូវផ្នែកដែលពាក់ព័ន្ធនៅក្នុងអនុស្សរណៈលើកមុន និងបានជូនដំណឹងថា ក្នុងសវនាការនាពេលរសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១២ អង្គជំនុំជម្រះនឹងលើកយកពិភាក្សានូវ "ការជំទាស់របស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ទៅលើឯកសារខាងលើ"[32]។

13. កាលពីថ្ងៃទី១២-១៥ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តីពីភាពអាចទទួលយកបានឯកសារទាំងឡាយដែលមាននៅក្នុងបញ្ជីកែសម្រួលក្នុងឧបសម្ព័ន្ធ A6-A11 និង A14-20[33]។ នៅពេលចាប់ផ្តើមសវនាការទាំងនេះ ប្រធានបានលើកឡើងថា សវនាការធ្វើឡើងពាក់ព័ន្ធនឹងឯកសារទាំងឡាយដែលមាននៅក្នុងកថាខណ្ឌ៣ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២[34] ដែលឯកសារទាំងអស់ មាននៅក្នុងឧបសម្ព័ន្ធ ៦-១១ និង ១៤-២០ នៃបញ្ជីឯកសារកែសម្រួល។ ក្រុមមេធាវីការពារក្តីទាំងអស់ បានធ្វើការជំទាស់ដោយផ្ទាល់មាត់ទៅនឹង

---

[29] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E172/1** កថាខណ្ឌ ២។

[30] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E172/1** កថាខណ្ឌ ៥។

[31] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្រោមកម្មវត្ថុ "បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់ (ថ្ងៃទី ១២ ដល់ ១៩ ខែ មីនា ឆ្នាំ ២០១២" ឯកសារ **E172/5** ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២។

[32] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E172/5** ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៥។

[33] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/46.1** ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២; ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/47.1** ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២; ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/48.1** ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២; ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/49.1** ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២; សូមមើលផងដែរ បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់ ឯកសារ **E172/5**, ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២។

[34] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/46.1** ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ៦២ (ភាសាអង់គ្លេស); មើលផងដែរ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/47.1** ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ២ (ភាសាអង់គ្លេស)។

ឯកសារនានាក្នុងអំឡុងពេលសវនាការទាំងនេះ ដោយរួមបញ្ចូលទាំងមេធាវីការពារក្តីផង[35]។ មេធាវីការពារក្តី គឺជាក្រុមមេធាវីការពារក្តីតែមួយគត់ដែលអះអាងថា ឯកសារ“ថ្មី” ដែលមាននៅក្នុងឧបសម្ព័ន្ធ មិនស្ថិតនៅក្រោមការពិភាក្សានៅក្នុងសវនាការនេះទេ[36]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងមេធាវីការពារក្តីថា ឯកសារទាំងនោះមិនមែនជាឯកសារ“ថ្មី” ទៀតទេ ដោយសារតែឯកសារទាំងនេះ ត្រូវបានដាក់ជូនមុនពេលចាប់ផ្តើមនៃសវនាការ និងបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាទទួលយកឯកសារទាំងនេះ ដែលមានលក្ខណៈស្រដៀងគ្នានឹងឯកសារផ្សេងទៀត ដែលមាននៅក្នុងឧបសម្ព័ន្ធ A៦-១១ និង A១៤-២០[37]។

---

[35] មើលឧទាហរណ៍ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/47.1** ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ២ ដល់ ២២ (ម៉ោង០៩:០៨ :៤៦) (ភាសាអង់គ្លេស)។

[36] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/47.1** ទំព័រ ៤ (ភាសាអង់គ្លេស) ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ មេធាវីការពារក្តីបានបញ្ជាក់ក្នុងតុលាការថា ៖ “ចំពោះឯកសារថ្មី និងក៏យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចរបស់ខ្លួនលេខ E172/5 ដែលបានបញ្ជាក់អំពីការកំណត់ចំពោះឯកសារថ្មីដែលនឹងត្រូវយកទៅពិភាក្សានៅក្នុងឧបសម្ព័ន្ធ២១ ដែលមាននីតិវិធីពិភាក្សាដោយឡែក មិនស្ថិតនៅក្នុងការដេញដោលនៅពេលនេះទេ។ ហើយអ្វីដែលជាការកត់សម្គាល់របស់ក្រុមមេធាវីការពារលោក ខៀវ សំផន ឃើញថា ឯកសារថ្មីនេះគឺមានរាយប៉ាយនៅគ្រប់ឧបសម្ព័ន្ធទាំងអស់ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា។ ដូច្នេះ បើយើងពិនិត្យទៅលើឯកសារថ្មីនេះគឺមានចំនួនរហូតទៅដល់ ៣៤១ ឯកសារ ហើយឯកសារទាំងនេះ ក្រុមមេធាវីការពារលោក ខៀវ សំផន ក៏មិនលើកយកមកពិចារណា យកមកពិភាក្សាដេញដោល ឬធ្វើការជំទាស់នៅពេលនេះទេ។ ដោយហេតុថា ឯកសារនោះមិនត្រូវពេលសម្រាប់យកមកសួរដេញដោលនៅក្នុងសវនាការនាពេលនេះ ហើយដែលយើងយល់ឃើញថា អង្គជំនុំជម្រះនឹងមានការបើកសួរដេញដោលសម្រាប់ឯកសារថ្មីទាំងនេះនៅសវនាការពេលក្រោយ"។

[37] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E1/47.1** ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ៧៣-(ម៉ោង១៣. ៥៥. ១៧) ៧៤ (អង់គ្លេស) *ខ្ញុំយល់ថា មេធាវីការពារក្តីរបស់ ខៀវ សំផន បានលើកឡើងថា តាមការយល់របស់ពួកគេ គឺឯកសារថ្មីត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ ២១ នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានោះ គឺមិនមែនជាកម្មវត្ថុនៃសវនាការក្នុងដំណាក់កាលនេះទេ។ ខ្ញុំគិតថា ត្រឹមត្រូវហើយ ដោយសារឯកសារនេះមិនមែនជាឯកសារថ្មីទេ វាគ្រាន់តែជាឯកសារដែលយើងខ្ញុំបានដាក់នៅក្នុងខែ មេសា ឆ្នាំ ២០១១ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចអំពីការកំណត់ពេលវេលាសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅពេលនោះគឺថា វាមិនទាន់មាននៅក្នុងសំណុំរឿងមែន។ ហើយខ្ញុំសូមស្នើថាឱ្យដាក់បញ្ចូលនៅក្នុងសំណុំរឿងនេះ ហើយគេបានពិនិត្យមើលទៅលើឧបសម្ព័ន្ធទាំង ២៨ នេះគឺមាននៅក្នុងឧបសម្ព័ន្ធ ២១ នេះ។* ខ្ញុំបានបញ្ជាក់ត្រង់ចំណុចនេះ ពីព្រោះថា ការដែលដាក់ឈ្មោះថា “ឯកសារថ្មី” នេះ គឺមិនត្រូវទេ នៅពេលដែលសវនាការចាប់ផ្តើមឡើង ជាមួយសវនាការបឋម។ បន្ទាប់ពីសវនាការបឋម វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង គឺនិយាយអំពីការហាមមិនទទួលយកនូវឯកសារថ្មី។ ខ្ញុំគិតថា ឯកសារទាំងអស់នេះគឺកំណត់ថាជាឯកសារថ្មីនៅក្នុងបញ្ជីរបស់យើងខ្ញុំ គឺនៅក្នុងឯកសារ -- យើងខ្ញុំបានដាក់ជូនមួយរយៈកន្លងមកហើយ។ ហើយយើងខ្ញុំសូមអញ្ជើញឱ្យអង្គជំនុំជម្រះមេត្តាពិនិត្យ និងពិចារណាទទួលយកឯកសារដែលដាក់នៅក្នុងឧបសម្ព័ន្ធនេះ។

14. កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនទាក់ទិននឹងការទទួលយកបាននៃឯកសារទាំងឡាយដែលមានក្នុងបញ្ជីកែសម្រួល នៅក្នុងឧបសម្ព័ន្ធ A១-A៥[38]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តីបានដាក់ជូននូវការជំទាស់ជាលាយលក្ខណ៍អក្សរ និងលើកឡើងថា "ក្រុមមេធាវីការពារក្តីទាំងអស់បានទទួលឱកាសក្នុងការជំទាស់ផ្ទាល់មាត់ទៅនឹងឯកសារ និងប្រភេទជាក់លាក់នៃឯកសារនានា..."[39]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសារ ដែលរួមបញ្ចូលទាំងឯកសារ"ថ្មី" លើកលែងតែឯកសារត្រង់ចំណុច ១២:៩ ដែលត្រូវបានចាត់ទុកថាមិនអាចជឿជាក់បាន និងមិនពាក់ព័ន្ធទៅនឹងការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ និងត្រង់ចំណុច ៣ ដែលនៅក្នុងពេលនោះមិនមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម[40]។

15. កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយ ទាក់ទិននឹងឯកសារ "ថ្មី" ដែលសហព្រះរាជអាជ្ញាបានស្នើសុំឲ្យដាក់បញ្ចូលនៅក្នុងសំណុំរឿង[41]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់អំពីភាពខុសគ្នារវាងប្រភេទនៃឯកសារ "ថ្មី"ទាំងពីរនេះ។ ប្រភេទទីមួយ គឺឯកសារថ្មីដែលស្នើសុំឲ្យទទួលយកនូវការដាក់ឯកសារចំនួនបី ក្រោយពេលចាប់ផ្តើមនៃសវនាការ អនុលោមតាមវិធាន៨៧(៤)[42]។ ប្រភេទទីពីរ គឺឯកសារទាំងឡាយដែលមិនទាន់មាននៅក្នុងសំណុំរឿង ប៉ុន្តែ "បានទទួលការអនុញ្ញាតឲ្យដាក់ក្នុងបញ្ជីឯកសារដែលភាគីបានស្នើសុំពីដំបូង ដោយអនុលោមតាមវិធាន ៨០(៣)(ឃ) (ទាក់ទិននឹងសំណុំរឿង ០០២ ទាំងមូល) និងបញ្ជីឯកសារក្រោយទៀត (ដែលបានបង្ហាញថា ឯកសារដែលនៅក្នុងបញ្ជីឯកសារដើមរបស់ខ្លួនពាក់ព័ន្ធនឹងសំណុំ

---

[38] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ **E185** ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ១។

[39] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185** ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៨។

[40] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185** ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កំណត់សម្គាល់ ៥៦ ទំព័រ ១៧ (ភាសាអង់គ្លេស)។ ឯកសារដែលមិនត្រូវបានទទួលយកទាំងនេះមាននៅក្នុង ឯកសារ **E185.2**។

[41] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ **E190** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៤(ក)(i), កថាខណ្ឌ ២៧ កថាខណ្ឌ ២៨; មើលផងដែរ ឧបសម្ព័ន្ធ ៖ ឯកសារថ្មីៗដែលបានកំណត់អត្តសញ្ញាណដោយភាគី នៅក្នុងបញ្ជីឯកសារដែលបានកែសម្រួល ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **E190.1**។

[42] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E190** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ១។

រឿង ០០២/០១"[43] ពោលគឺឯកសារដែលនៅក្នុងបញ្ជីឯកសារដំបូង និងក្រោយមកក្នុងបញ្ជីឯកសារដែលកែសម្រួល។

16. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ក្នុងចំណោមឯកសារថ្មីចំនួន ៤៤៨ នៅក្នុងបញ្ជីកែសម្រួល មានឯកសារចំនួន ៤៤៤ ដែលត្រូវបាន "ដាក់បញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ឬ ត្រូវបានភ្ជាប់ជាមួយឯកសារផ្សេងទៀត ដូច្នេះ ភាគី និងអង្គជំនុំជម្រះអាចពិនិត្យមើលឯកសារទាំងនេះបាន"[44]។ អង្គជំនុំជម្រះសាលាដំបូងបានដាក់ឯកសារទាំង ៤៤៤ ក្នុងចំណោមឯកសារថ្មីចំនួន ៤៤៨ ចូលទៅក្នុងសំណុំរឿងដោយចាត់ទុកថា "*តាមការពិនិត្យមើលជាបឋម* នាំទៅដល់ការបញ្ជាក់ការពិត"[45] ដែលឯកសារទាំងនេះមានដាក់ភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃបញ្ជីកែសម្រួលនេះ ដោយមិនបានទទួលយកជាផ្លូវការទេ[46]។

17. នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនលើការទទួលយកឧបសម្ព័ន្ធ ក៦ ដល់ ក១១ និង ក១៤-ក២០ នៅក្នុងបញ្ជីកែសម្រួលរបស់សហព្រះរាជអាជ្ញាដាក់ក្នុងសំណុំរឿង[47]។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា សេចក្តីសម្រេចនេះ "ត្រូវបានធ្វើឡើងបន្ទាប់ពីសវនាការដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងការជំទាស់ទៅនឹងការទទួលយកឯកសារទាំងនេះ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង"[48]។ នៅក្នុងសេចក្តីសង្ខេបបន្ថែមអំពីប្រវត្តិនីតិវិធីពាក់ព័ន្ធនឹងឱកាសផ្តល់លទ្ធភាពធ្វើការជំទាស់ទៅនឹងបញ្ជីកែសម្រួលនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា៖

---

[43] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E190** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ១។

[44] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E190** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៧។

[45] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E190** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៧។

[46] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E190** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៤(ក)(i), កថាខណ្ឌ ២៧ កថាខណ្ឌ ២៨; មើលផងដែរ ឯកសារ **E190.1** ឧបសម្ព័ន្ធ ៖ ឯកសារថ្មីៗដែលបានកំណត់ដោយភាគីនៅក្នុងបញ្ជីឯកសារដែលបានកែសម្រួល ខែ កក្កដា ឆ្នាំ ២០១១។

[47] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងឧបសម្ព័ន្ធ A1-A5 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងៗទៀត ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។

[48] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១។

*ភាគីត្រូវបានផ្តល់ឱកាសលើកដំបូងដើម្បីដាក់ការជំទាស់ទៅនឹងឯកសារ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ A1 ដល់ A5 ក្នុងអំឡុងពេលសវនាការពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ ("សវនាការដេញដោលលើឯកសារភស្តុតាងលើកទីមួយ")។...ការជំទាស់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-20 របស់សហព្រះរាជអាជ្ញា...ត្រូវបានលើកឡើងក្នុងសវនាការពីថ្ងៃទី១២ ដល់ ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១២ ("សវនាការដេញដោលលើឯកសារភស្តុតាងលើកទីបី")[49]* ។

18. អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់បន្ថែមទៀតថា "បន្ថែមពីលើការជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួន មេធាវីការពារក្តីគ្រប់ក្រុមទាំងអស់មានឱកាសដាក់ការជំទាស់ដោយផ្ទាល់មាត់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 នៅក្នុងសវនាការដេញដោលលើឯកសារភស្តុតាងលើកទីបី"[50]។ អង្គជំនុំជម្រះសាលាដំបូងគូសបញ្ជាក់ថា ខ្លួន "បានពិចារណាឡើងវិញទៅលើឯកសារនីមួយៗដែលមាននៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 និងបានពិចារណាចំពោះការជំទាស់នានាទៅលើឯកសារទាំងនោះ ដែលភាគីបានលើកឡើង"[51]។

19. ក្រោយពេលកត់សម្គាល់ឃើញម្តងទៀតថា ខ្លួនបានពិនិត្យ "ទៅលើឯកសារទាំងអស់ដែលមានក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20" អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលយកឯកសារទាំងអស់នៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 នៃបញ្ជីកែសម្រួល លើកលែងតែឯកសារចំនួន ៧ ដែលត្រូវបានពិចារណាថាពុំជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងដែលមាននៅក្នុងឧបសម្ព័ន្ធ គ នៃសេចក្តីសម្រេចនោះ[52]។ ប៉ុន្តែ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺមានកថាខណ្ឌមួយនៅក្នុងសេចក្តីសន្និដ្ឋាននៃអង្គជំនុំជម្រះសាលាដំបូងដែលបានលើកឡើងថា ផ្ទុយពីការបញ្ជាក់ទាំងអស់នៅក្នុងសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងបែរជា "ពន្យារសេចក្តីសម្រេចរបស់ខ្លួនទៅលើឯកសារចំនួនជាង ៤០០ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ ២១ របស់សហព្រះរាជអាជ្ញា ស្របតាមសេចក្តីសម្រេចលើឯកសារថ្មីៗ។ ការលើកអំណះអំណាងតទល់គ្នាពាក់ព័ន្ធនឹងឯកសារទាំងនេះនឹងត្រូវកំណត់កាលបរិច្ឆេទធ្វើក្នុងពេលដ៏ខ្លីខាងមុខ និងសេចក្តីសម្រេចមួយពាក់ព័ន្ធនឹងឯកសារទាំងនោះនឹងត្រូវចេញក្នុងពេលវេលាសម

[49] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២-៣។

[50] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥។

[51] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១១។

[52] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៨; ឧបសម្ព័ន្ធ គ ៖ ឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ឯកសារ **E185/1.3**។

ស្រប”[53]។ ករណីនេះធ្វើឲ្យមានការភ្ញាក់ផ្អើលមិនដោយសារតែសវនាការដេញដោលលើឯកសារបានធ្វើឡើងរួចហើយនោះទេ ក៏ប៉ុន្តែវាក៏ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងដដែលៗថា ខ្លួនកំពុងធ្វើការពិចារណាទទួលយកឯកសារទាំងអស់នេះ (និយាយឲ្យជាក់ស្តែងទៅ គឺរួមទាំងឯកសារ “ថ្មីៗ” ផងដែរ) នៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 ហើយអង្គជំនុំជម្រះសាលាដំបូងបានពន្យារសេចក្តីសម្រេចដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង “ពិចារណាថា ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញាថាជាឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ”[54]។

20. នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តី អៀង សារី បានដាក់លិខិតមួយច្បាប់ជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឲ្យ “បញ្ជាក់បំភ្លឺថាតើក្រុមមេធាវីការពារក្តីអាចនៅតែបន្តជំទាស់ទៅនឹងឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ A21 របស់ ក.ស.ព (និងឯកសារថ្មីៗរបស់ភាគីផ្សេងទៀតដែលបានដាក់អនុលោមតាមវិធាន ៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង”[55]។ លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី បានកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីបាន “ជំទាស់ទៅនឹងឯកសារនានាដែលមាននៅក្នុងឧបសម្ព័ន្ធ A21 ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ និងបន្ទាប់មកនៅក្នុងពេលធ្វើសវនាការផ្តល់ទឡ្ហីករណ៍ដោយផ្ទាល់មាត់នៅក្នុងអំឡុងថ្ងៃទី១៦ ដល់ ថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១២ និងនៅអំឡុងថ្ងៃទី១២ ដល់ ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១២”[56]។ ក្រុមមេធាវីការពារក្តី អៀង សារី ក៏បានសង្កេតឃើញថា សេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូងនាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ក៏បានលើកឡើងពាក់ព័ន្ធនឹងការទទួលយកឯកសារ “ថ្មីៗ” ដែលទំនងជា “មានលក្ខណៈផ្ទុយគ្នា”[57] ដូចដែលសហព្រះរាជអាជ្ញាបានកត់សម្គាល់រួចហើយនៅក្នុងកថាខណ្ឌពីមុន។

21. នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រោយពីបានបកស្រាយលិខិតពីក្រុមមេធាវីការពារក្តី អៀង សារី ថាជាសំណើសុំនូវ “ឱកាសដើម្បីលើកការជំទាស់បន្ថែមទៅនឹងឯកសារថ្មីៗ ដែលបានស្នើសុំដោយសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធ A21 និងឯកសារថ្មីៗរបស់ភាគីផ្សេងទៀត” អង្គជំនុំជម្រះ

[53] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២២។

[54] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ **E185/1** ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ១០ ។

[55] លិខិតរបស់ក្រុមមេធាវីការពារលោក អៀង សារី ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[56] លិខិតរបស់ក្រុមមេធាវីការពារលោក អៀង សារី ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ទំព័រ ១។

[57] លិខិតរបស់ក្រុមមេធាវីការពារលោក អៀង សារី ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៨។

សាលាដំបូងក៏ព្រមទទួលយកសំណើសុំនេះ[58]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ("ក្រុមមេធាវីការពារក្តី") បានដាក់ការជំទាស់របស់គេ[59] ("ឯកសារជំទាស់បន្ថែម") ដែលត្រូវបានជូនដំណឹងឲ្យភាគីបានជ្រាបនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣។

## III. អំណះអំណាង

### ក. មេធាវីការពារក្តីមានឱកាសយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីដាក់ការជំទាស់ចំពោះការទទួលយកឯកសារ "ថ្មី" នានាដែលមាននៅក្នុងបញ្ជីដែលបានកែសម្រួលឡើងវិញ

22. មេធាវីការពារក្តីយល់ស្របថា ឯកសារក្នុងឧបសម្ព័ន្ធ២១ នៃបញ្ជីឯកសារដើម ត្រូវបានបែកនៅក្នុងចំណោមឧបសម្ព័ន្ធ១-១១ និង ១៤-២០ ជាបញ្ជីឯកសារដែលបានកែសម្រួលឡើងវិញដែលជាកម្មវត្ថុនៃសវនាការដេញដោល[60]។ ប៉ុន្តែ មេធាវីការពារក្តីតវ៉ាថា ឯកសារ "ថ្មី" ដែលមាននៅឧបសម្ព័ន្ធនិមួយៗទាំងនេះ មិនដាក់បញ្ចូលនៅក្នុងការដេញដោលទេ នៅពេលឧបសម្ព័ន្ធនិមួយៗត្រូវបានលើកយកមកពិភាក្សា[61] ហើយពួកគេបានចោទប្រកាន់សហព្រះរាជអាជ្ញាថា កំពុងតែធ្វើសកម្មភាពក្នុងគំនិតមិនសុចរិតតាមរយៈការអះអាងថា មានឱកាសដើម្បីជំទាស់ទៅនឹងឯកសារទាំងនោះតាំងពីដំបូង[62]។

23. ដោយសារនេះជាបញ្ហាបច្ចេកទេស គេត្រូវកត់សំគាល់ថា បញ្ជីឯកសារដែលបានកែសម្រួលឡើងវិញមិនមានឧបសម្ព័ន្ធ២១ទេ។ ឧបសម្ព័ន្ធ២១ត្រូវបានដាក់បញ្ចូលជាមួយនឹងបញ្ជីឯកសារដើមតែប៉ុណ្ណោះ។

24. បើនិយាយអំពីសារធាតុនៃការទាមទារវិញ មេធាវីការពារក្តីខកខានមិនបានបញ្ជាក់ភ័ស្តុតាងចំពោះអំណះអំណាងរបស់ខ្លួនដែលថា ការជំទាស់ទៅនឹងឯកសារ "ថ្មី" មិនត្រូវបានធ្វើសវនាការទាក់ទងនឹងឧបសម្ព័ន្ធនិមួយៗ នៅក្នុងអំឡុងនៃសវនាការលើឯកសារ ថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០១២ និង

---

[58] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E246/1** "ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់" ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៤។

[59] សេចក្តីជំទាស់មិនទទួលយកឯកសារថ្មីរបស់ ខៀវ សំផន ឯកសារ **E246/1/1** ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយបានជូនដំណឹងកាលពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣។

[60] **E246/1/1**, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ត្រង់កថាខណ្ឌទី៣។

[61] **E246/1/1**, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ត្រង់កថាខណ្ឌទី២-៤។

[62] **E246/1/1** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ត្រង់កថាខណ្ឌទី១៧។

ថ្ងៃទី១២-១៥ ខែមីនា ឆ្នាំ២០១២[63] នោះឡើយ។ មានតែក្រុមមេធាវីការពារក្តីមួយគត់ ដែលបានបញ្ជូនអំណះអំណាងថា សវនាការផ្ទាល់មាត់ស្តីពីភាពអាចទទួលយកបាននៃឯកសារក្នុងឧបសម្ព័ន្ធទាំងនេះមិនបានដាក់បញ្ចូលឯកសារ "ថ្មី" ដែលមាននៅក្នុងឧបសម្ព័ន្ធទាំងនោះ គឺមេធាវីការពារក្តីនេះឯង ហើយបន្ទាប់ពីនោះ គឺទាក់ទងតែនឹងសវនាការក្នុងខែមីនា ឆ្នាំ២០១២ ដែលពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ៦-១១ និង១៤-២០[64] ប៉ុណ្ណោះ មិនមែនសវនាការខែមករា ឆ្នាំ២០១២ ដែលពាក់ព័ន្ធនឹងឧបសម្ព័ន្ធ១-៥ ឡើយ។ ជាការបន្ថែម ក្នុងអំឡុងសវនាការទាំងអស់នោះ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់មេធាវីការពារក្តីនេះថា សហព្រះរាជអាជ្ញាមិនចែករំលែកសេចក្តីបកស្រាយរបស់មេធាវីនេះថា សវនាការនឹងបញ្ចូលឯកសារ"ថ្មី" នោះឡើយ ដោយថ្លែងថា៖ "ឯកសារទាំងនោះត្រូវដាក់នៅចំពោះមុខលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីរួចហើយ។ ឯកសារទាំងនោះបានដាក់នៅចំពោះមុខអស់លោក លោកស្រីនាពេលកន្លងមក។ ឯកសារទាំងនោះគឺជាកម្មវត្ថុនៃសវនាការទាំងនេះ ហើយយើងខ្ញុំក៏សូមអញ្ជើញឲ្យអង្គជំនុំជម្រះពិចារណាទទួលយកឯកសារទាំងនោះរួមទាំងឯកសារផ្សេងទៀតដែលមាននៅក្នុងឧបសម្ព័ន្ធទាំងអស់នោះ"[65]។

25. លើសពីនេះ ការពិនិត្យឡើងវិញមួយទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង នៅមុនសវនាការលើឯកសារក្នុងខែមករា និងខែមីនា ឆ្នាំ២០១២ បង្ហាញឲ្យឃើញថា ចេតនារបស់អង្គជំនុំជម្រះសាលាដំបូង គឺធ្វើយ៉ាងណាចង់ឲ្យឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធទាំងនេះ (មិនរួមបញ្ចូលឧបសម្ព័ន្ធ១២ និង ១៣) ត្រូវបានលើកយកមកដេញដោលនៅក្នុងសវនាការទាំងនោះ។ នៅក្នុងអនុស្សរណៈដំបូងរបស់ខ្លួនចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២[66] អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ខ្លួនមានបំណង "ដាក់ប្រភេទឯកសារសហកាលកម្ពុជាប្រជាធិបតេយ្យទាំងមូលដូចខាងក្រោមនេះនៅចំពោះមុខខ្លួន ដោយអនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង" ដែលយោងសំដៅឧបសម្ព័ន្ធ១-១០[67]។ សម្រាប់ឧបសម្ព័ន្ធនិមួយៗទាំងនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់

---

[63] **E246/1/1** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ត្រង់កថាខណ្ឌទី២។

[64] **E1/47.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់ អជតក, ១៣ មីនា ២០១២, ត្រង់ម៉ោង 09.14.41, ERN អង់គ្លេស 00791136។

[65] **E1/47.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរបស់ អជតក, ១៣ មីនា ២០១២, ទំព័រទី៧៤។

[66] **E159** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "កាលវិភាគសម្រាប់សវនាការផ្ទាល់មាត់លើឯកសា (១៦-១៩ ខែមករា ឆ្នាំ២០១២)" ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២។

[67] **E159** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌទី៨។

ពីចំនួនឯកសារដែលពាក់ព័ន្ធ[68]។ ចំនួនឯកសារដែលបានចុះបញ្ជីសម្រាប់ឧបសម្ព័ន្ធនិមួយៗ រួមមានឯកសារ "ថ្មី"។ នៅក្នុងអនុស្សរណៈដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងបន្ថែមថា "ឯកសារទាំងអស់ក្នុងប្រភេទដូចបានជម្រាបជូនខាងលើ ដែលមិនមានការជំទាស់ក្នុងពេលវេលាកំណត់ជាផរមាន ត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ"[69]។

26. ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈទីពីរស្ដីពីក្រុមសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញបន្ទាប់ដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង ០០២/១ និងបានថ្លែងពីចេតនារបស់ខ្លួន ដើម្បីពិភាក្សាលើ "ឯកសារនៅសល់ទាំងអស់ដែលបានស្នើដាក់ដោយភាគីនៅចំពោះមុខអង្គជំនុំជម្រះ" និងថា "ហេតុដូច្នេះ សវនាការនេះបញ្ចប់កិច្ចពិភាក្សាលើឯកសារទាំងអស់ដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយភាគីទាំងអស់ ក្នុងសំណុំរឿង ០០២/១"[70]។

27. អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង លេខ E172/1[71] ដែលទាក់ទងនឹងឯកសារសម្រាប់សវនាការចាប់ផ្ដើមពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ (ក៦-ក១១ និង ក១៤-ក២០) អង្គជំនុំជម្រះសាលាដំបូងបានថ្លែងពីចេតនារបស់ខ្លួន ដើម្បីស្ដាប់ការជំទាស់ដោយផ្ទាល់មាត់ "ចំពោះឯកសារទាំងអស់ដែលភាគីបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះថា មានការជាប់ពាក់ព័ន្ធក្នុងសវនាការនៅក្នុងសំណុំរឿង ០០២/១ (E109/1.1, E109/2.1, E109/4, E109/6.2) ហើយដែលមកដល់ពេលនេះ មិនទាន់បានពិភាក្សានៅក្នុងសវនាការនៅឡើយ"[72]។ ជាថ្មីម្ដងទៀត អង្គជំនុំជម្រះសាលាដំបូងបានរាយឈ្មោះចំនួនឯកសារនៅក្នុងឧបសម្ព័ន្ធដែលពាក់ព័ន្ធនិមួយៗ ដែលនឹងត្រូវពិចារណានៅពេលសវនាការផ្ទាល់មាត់ ដែលនៅក្នុងចំនួនឯកសារទាំងនោះមានបញ្ចូលឯកសារ "ថ្មី"[73]។ អង្គជំនុំជម្រះបានថ្លែងបន្ថែមថា ក្នុងចំនួនឯកសារនិមួយៗទាំងនេះ តំណាងឲ្យ "ឯកសារទាំងអស់" ដែលបានចុះក្នុងបញ្ជីឯកសារដើម ដែលបានដាក់បញ្ចូលក្នុងបញ្ជីឯកសារដែលបានកែសម្រួលឡើងវិញផងដែរ[74]។ ឯកសារ E172/5

---

[68] **E159** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌទី៨

[69] **E159** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌទី៨

[70] **E172** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ក្រុមសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវស្ដាប់សវនាការ សំណុំរឿង០០២/០១" ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ ទំព័រ១។

[71] **E172/1** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សវនាការផ្ទាល់មាត់បន្ថែមលើឯកសារ(ចាប់ផ្ដើម ១២ មីនា ២០១២) " ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។

[72] **E172/1** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌទី១។

[73] **E172/1** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌទី២។

[74] **E172/1** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌទី២។

បានបញ្ជាក់ឡើងវិញពីចំណុចនេះ ព្រមទាំងបានកត់សំគាល់ថា វគ្គសវនាការនាវេលារសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ សម្រាប់តែមាន "ការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះឯកសារទាំងអស់ដូចខាងលើ"[75]។ ទោះបីឯកសារ E172/5 ក៏បាននិយាយផងដែរថា "ការណែនាំបន្ថែមទាក់ទងនឹងការពិភាក្សាដេញដោលលើឯកសារថ្មីទាំងអស់ ដែលមានក្នុងបញ្ជីឯកសាររបស់ភាគី ត្រូវអនុវត្តទៅតាមពេលវេលាសមស្រប..."[76] ដោយសារឯកសារ "ថ្មី" នៅក្នុងបញ្ជីឧបសម្ព័ន្ធ ក១-ក៥ របស់សហព្រះរាជអាជ្ញា ត្រូវបានដេញដោលរួចហើយក្តី ក៏សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការបកស្រាយដ៏ល្អបំផុតត្រង់ចំណុចនេះគឺថា វាជាសេចក្តីយោងមួយទៅរកឯកសារនានាដែលបានដាក់ដោយភាគី បន្ទាប់ពីសវនាការបានចាប់ផ្តើម និងថាមិនទាន់បានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសារដើមរបស់ភាគីទេ។ ឯកសារថ្មីដែលនៅសល់ទាំងនេះត្រូវបានដេញដោលជាក្រោយ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣[77]។

28. អាស្រ័យហេតុនេះ អនុស្សរណៈទាំងអស់នេះបញ្ជាក់ច្បាស់ណាស់ថា ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ១-១១ និង១៤-២០ គឺជាកម្មវត្ថុនៃការតវ៉ានៅក្នុងបណ្តាសវនាការនិមួយៗ។ ការបញ្ជាក់អះអាងបន្ថែមទៀតដែលថា ឯកសារទាំងនេះត្រូវបានដាក់ជាកម្មវត្ថុនៃការដេញដោលរួចហើយនោះ គឺជាការពិតដែលថាអង្គជំនុំជម្រះសាលាដំបូងចាប់ពីពេលនោះមក បានចេញសេចក្តីសម្រេចរបស់ខ្លួនដោយទទួលយកឯកសារភាគច្រើនបំផុតនៅក្នុងឧបសម្ព័ន្ធ១-៥ នៃបញ្ជីឯកសារដែលបានកែសម្រួលឡើងវិញ រួមទាំងឯកសារ "ថ្មី" នៅក្នុងឧបសម្ព័ន្ធទាំងនោះ[78]។

29. សហព្រះរាជអាជ្ញាក៏សូមរំលឹកដែរថា ជាបន្ថែមពីលើការដាក់ការជំទាស់ដោយផ្ទាល់មាត់ ក្រុមមេធាវីការពារក្តីក៏បានដាក់ការជំទាស់ដែលពាក់ព័ន្ធជាលាយលក្ខណ៍អក្សរកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ [79] និងពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២[80] ថែមទៀត។ តាមពិត ក្នុងលិខិតរបស់ក្រុមមេធាវីការពារជន

---

[75] **E172/5** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "បច្ចុប្បន្នភាពអនុស្សរណៈ សម្រាប់សម្រាប់សវនាការឯកសារបន្ទាប់(ចាប់ផ្តើម ១២-១៩ មីនា ២០១២) " ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌទី៥។

[76] **E172/5** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌទី៧។

[77] **E1/162.1** អនុស្សរណៈប្រតិចារឹកដំណើរការនីតិវិធី ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣។

[78] **E185** សេចក្តីសម្រេចលើការជំទាស់ចំពោះឯកសារ ចុះថ្ងៃទី៩ មេសា ២០១២។

[79] ឯកសារលេខ **E131/16** ការជំទាស់របស់ ខៀវ សំផន ចំពោះការទទួលយកឯកសាររបស់ភាគីដទៃទៀត សម្រាប់សវនាការដំណាក់កាលដំបូង ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១។

[80] ឯកសារលេខ **E131/1/11** ការជំទាស់របស់ ខៀវ សំផន ថ្ងៃទី៥ ខែមករា ឆ្នាំ២០១២។

ជាប់ចោទ អៀង សារី ដែលត្រូវបានអនុញ្ញាតនោះ បានបើកឲ្យធ្វើការជំទាស់ជាបន្ថែមទៀត ដោយទទួលស្គាល់ថា ក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី ត្រូវបានបើកឱកាសឲ្យធ្វើការជំទាស់រួចហើយ ទៅនឹងឯកសារ "ថ្មីៗ" ដែលត្រូវបានចែកឲ្យតាមរយៈឧបសម្ព័ន្ធនានា ដោយបានថ្លែងថា៖ "យើងខ្ញុំសូមជំទាស់ទៅនឹងឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធទី២១ ជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ និងបន្ទាប់មក ជាថ្មីម្តងទៀត នៅក្នុងអំឡុងពេលនៃការលើកអំណះអំណាងដោយផ្ទាល់មាត់ កាលពីថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០១២ និងពីថ្ងៃទី១២-១៥ ខែមករា ឆ្នាំ២០១២"[81]។ ក្រុមមេធាវីការពារជនជាប់ចោទ ខៀវ សំផន ក៏មានឱកាសដូចគ្នាទាំងនេះផងដែរ។

30. ដូចនេះ គឺជាការច្បាស់លាស់ណាស់ថា ក្រុមមេធាវីការពារក្តីនានាសុទ្ធតែត្រូវបានផ្តល់ឱកាសឲ្យរួចហើយ ដើម្បីធ្វើការជំទាស់ទៅនឹងការទទួលយកនូវឯកសារ "ថ្មី" ទាំងឡាយដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធនានាដែលបានពិនិត្យឡើងវិញរួចរបស់សហព្រះរាជអាជ្ញា។ គឺជាការបកស្រាយរបស់ក្រុមមេធាវីការពារក្តីតែឯងប៉ុណ្ណោះ ក្រុមដែលមិនទាន់ត្រូវបានចូលរួម ដោយសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ឬមួយក៏ក្រុមមេធាវីការពារក្តីផ្សេងទៀត ដែលសវនាការដេញដោលនៅខែមីនា ឆ្នាំ២០១២ លើបញ្ជីដែលបានពិនិត្យឡើងវិញរួច មិនបានដាក់បញ្ចូលនូវឯកសារ "ថ្មី" នានាដែលមាននៅក្នុងនោះ។ ក្នុងខណៈពេលដែលក្រុមមេធាវីការពារក្តីអាចជ្រើសយកដោយសេរី ក្នុងការមិនលើកឡើងនូវឯកសារមួយចំនួនបាន នៅក្នុងពេលដែលត្រូវបានគេផ្តល់ឱកាសឲ្យធ្វើការជ្រើសរើសនោះ គឺមិនមែនមានន័យថា ការប្រកាសជូនដំណឹងជាឯកតោភាគីរបស់ពួកគេដែលផ្តល់ឲ្យពួកគេនូវឱកាសណាមួយជាបន្ថែមទៀតឲ្យធ្វើដូច្នេះនៅពេលក្រោយទៀតនោះឡើយ។ ក្រុមមេធាវីការពារក្តីមានសិទ្ធិក្នុងការទទួលបាននូវឱ*កាស* ដើម្បីលើកនូវអំណះអំណាង ដើម្បីតទល់គ្នាទាក់ទងនឹងឯកសារនានាស្តីពីថាតើពួកគេក្តាប់យកឱកាសនោះ គឺជាជម្រើសរបស់ពួកគេ ដែរ ឬក៏អត់។

31. លើសពីនេះ ដោយសារតែដូចខាងលើនេះ ទើបបានជាមានពាក្យនិយាយបង្កាច់បំផ្លើសរបស់ក្រុមមេធាវីការពារក្តីអំពីក្រមសីលធម៌របស់សហព្រះរាជអាជ្ញាដែលលើកឡើងថា សហព្រះរាជអាជ្ញាបានធ្វើសកម្មភាពដោយគំនិតមិនល្អនៅពេលកត់សម្គាល់ពីឱកាសសម្រាប់ធ្វើការជំទាស់ ដែលមេធាវីការពារក្តីបានដាក់-គឺជាការគួរឲ្យសោកស្តាយ និងបង្ហាញឲ្យឃើញពីគ្មានមូលដ្ឋានយ៉ាងពិតប្រាកដ។

[81] លិខិតពីក្រុមមេធាវីការពារក្តីរបស់ អៀង សារី ចុះថ្ងៃទី៦ កុម្ភៈ ២០១៣, ទំព័រ១។

សហព្រះរាជអាជ្ញាក៏បានស្នើជាសំណួរអំពីភាពគួរឲ្យជឿទុកចិត្តបាន ចំពោះការលើកឡើងទាំងស្រុង របស់ក្រុមមេធាវីការពារក្តី។

### ខ. រាល់ ឯកសារ "ថ្មី" ទាំងអស់ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីដែលពិនិត្យឡើងវិញ រួចហើយ ត្រូវបាន និងកំពុងតែមានស្រាប់សម្រាប់ក្រុមមេធាវីការពារក្តីងាយរកបាន

32. ក្រុមមេធាវីការពារក្តីបានលើកឡើងថា ពួកខ្លួនមិនមានសិទ្ធិក្នុងការចូលទៅពិនិត្យមើលឯកសារ "ថ្មី" ទាំងឡាយដែលមាននៅក្នុងបញ្ជីដែលបានពិនិត្យឡើងវិញ នៅមុនពេលធ្វើសវនាការដោយផ្ទាល់មាត់ លើឧបសម្ព័ន្ធទី១-១១ និងទី១៤-២០ ដែលហេតុដូចនេះ ទើបបានជាពួកគេមិនអាចធ្វើការជំទាស់ នឹងឯកសារទាំងនេះបាន[82]។ សហព្រះរាជអាជ្ញាបានធ្វើការជូនដំណឹងដល់ក្រុមមេធាវីការពារក្តីនានា យ៉ាងហោចណាស់ក៏ចាប់ពីដើមខែវិច្ឆិកា ឆ្នាំ២០១១ មកដែរ ថារាល់ឯកសារទាំងអស់ រួមទាំងឯកសារ "ថ្មី" ក្នុងនោះផង អាចរកមើលបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ[83] ដែលអង្គជំនុំជម្រះបាន បញ្ជាក់[84]។ ហេតុដូចនេះគឺជាអំណះអំណាងនេះគ្មានអង្គសេចក្តីទេ។

### គ. ទោះបី ប្រសិនបើអង្គជំនុំជម្រះពិចារណាការជំទាស់បន្ថែម នោះសហព្រះរាជអាជ្ញាកត់សម្គាល់ផងដែរថា ការជំទាស់ភាគច្រើនរបស់ក្រុមមេធាវីការពារក្តីមិនមានមូលដ្ឋានត្រឹមត្រូវ

33. អំណះអំណាងភាគច្រើនបំផុតដែលបានបញ្ជូនមកដោយក្រុមមេធាវីការពារក្តី គឺទាក់ទងនឹងឯកសារ ទាំងឡាយដែលលែងទទួលរងនូវការជំទាស់ជាបន្តទៅទៀត។

#### *i. ការច្រានចោលនូវឯកសារចំនួន២៩ ពីក្នុងបញ្ជីឯកសារដើម របស់ការិយាល័យសហព្រះរាជអាជ្ញា E9/31*

34. សវនាការស្តីពីភាពអាចទទួលយកបាននៃឯកសារដែលបានធ្វើឡើងមកទល់ពេលនេះ បានលើកយក មកពិភាក្សាលើឯកសារដែលបានលើកស្នើនៅក្នុងបញ្ជីឯកសារដែលបានពិនិត្យឡើងវិញរួច (ឯកសារ លេខ E109/4)។ ឯកសារចំនួន២៩ ដែលក្រុមមេធាវីការពារក្តីបានជំទាស់មិនឲ្យមាននៅក្នុង

---

[82] ឯកសារលេខ **E246/1/1** ការជំទាស់របស់ ខៀវ សំផន ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ត្រង់កថាខណ្ឌទី១៧។

[83] ឯកសារលេខ **E131/19** ចម្លើយតបរួមរបស់ កសព ទៅនឹងការជំទាស់ទៅនឹងបញ្ជីឯកសាររបស់ សហព្រះរាជអាជ្ញាសម្រាប់សវនាការលើក ដំបូង, ចុះថ្ងៃទី១ ធ្នូ ២០១១, កថាខណ្ឌទី៥១។

[84] **E190** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ២៧។

ឧបសម្ព័ន្ធទី២១ ក្នុងបញ្ជីដើម ប៉ុន្តែមិនត្រូវបានសហព្រះរាជអាជ្ញារក្សាទុកដដែល នៅក្នុងបញ្ជីដែលបានពិនិត្យឡើងវិញរួចរបស់ខ្លួននោះទេ ហេតុដូចនេះវាមិនមែនជាការត្រឹមត្រូវក្នុងការដាក់ការជំទាស់នៅទីនេះនោះឡើយ។ ឯកសារទាំងនេះរួមមាន៖

- ឯកសារលេខ E246/1/1.2, លេខ ៤៧៩-៤៨០ (ក៏ពីដំបូង ត្រូវបានដាក់ចូលនៅក្នុងបញ្ជី ក្នុងខែមេសា ឆ្នាំ២០១១ ផងដែរ ក្នុង**ឧបសម្ព័ន្ធទី៨**, នៅក្រោមលេខ៤ និងលេខ៩២)[85]។
- ឯកសារលេខ E246/1/1.2, លេខ៤៣៩ (ពីដំបូងក៏ត្រូវបានដាក់ចូលនៅក្នុងបញ្ជី ក្នុងខែមេសា ឆ្នាំ២០១១ ផងដែរ ក្នុង**ឧបសម្ព័ន្ធទី៩**, នៅក្រោមលេខ១៩)។
- ឯកសារលេខ E246/1/1.2, លេខ៣៩៨, ៤០១, ៤១៩, ៤៣០, ៤៣១, ៤៣២, ៤៣៣, ៤៣៣, ៤៣៥ (ពីដំបូងក៏ត្រូវបានដាក់ចូលនៅក្នុងបញ្ជីក្នុងខែមេសា ឆ្នាំ២០១១ ផងដែរ ក្នុង**ឧបសម្ព័ន្ធទី១០**, នៅក្រោមលេខ៤២២, ៣០, ២៥៩, ៤៤០, ៤២៤, ៤៤១, ៤២៣, ២៥១)។
- ឯកសារលេខ E246/1/1.2, លេខ ៧៩,៨៩ , ៩៦, ១០៧, ១៣១, ១៣៥, ១៤៣, ១៥០, ១៥៤, ១៥៩, ១៦៧, ១៦៨ (ពីដំបូងក៏ត្រូវបានដាក់ចូលនៅក្នុងបញ្ជី ក្នុងខែមេសា ឆ្នាំ២០១១ ផងដែរ ក្នុង**ឧបសម្ព័ន្ធទី១៨**, នៅក្រោមលេខ៩២, ១២៤, ១៤១, ១៦២, ២៩៦, ៣០២, ៣១២, ៣៥១, ៣៥៥, ៣៧២, ៥០០, ៥១៨)។
- ឯកសារលេខ E246/1/1.2, លេខ២២២ (ពីដំបូងក៏ត្រូវបានដាក់ចូលនៅក្នុងបញ្ជីក្នុងខែមេសា ឆ្នាំ២០១១ ផងដែរ ក្នុង**ឧបសម្ព័ន្ធទី១៩**, នៅក្រោមលេខ១២៧)។

35. បន្ថែមពីលើនេះ ក្នុងចំណោមឯកសារ "ថ្មី"ទាំង ៤៥២ ឯកសារដែលរាយពាសពេញនៅក្នុងឧបសម្ព័ន្ធទី១-២០ ដែលភ្ជាប់ជាមួយនឹងឯកសារលេខ E109/4 អង្គជំនុំជម្រះបានចង្អុលបង្ហាញនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ឯកសារលេខ E190 ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ថា មានឯកសារ៣ ក្នុងនោះត្រូវបានដាក់ជូនចំពោះមុខអង្គជំនុំជម្រះរួចហើយ រីឯឯកសារមួយផ្សេងទៀត ត្រូវបាន កសព ដាក់បញ្ចូលនៅក្នុងបញ្ជីចំនួនពីរដងជាន់គ្នាដោយភាន់ច្រឡំ[86] ។

### *ii. ការច្រានចោលនូវឯកសារ"ថ្មី"ចំនួន៣៤ ពីក្នុងបញ្ជីឯកសារ លេខE109/4*

85 ឯកសារទាំងពីរនោះត្រូវបានស្នើឡើងដោយ កសព ទាក់ទងទៅនឹងការជម្លៀសប្រជាជន-ដំណាក់កាលទីមួយ, តារាង ឯកសារលេខ **E223/2/1.2**, លេខ៤០ & ៧០ ហើយដែលត្រូវបានពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ កាលពីក្នុងខែមករា ២០១៣។

86 ឯកសារលេខ **E190**, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារថ្មី និងបញ្ហាផ្សេងទៀតដែលទាក់ទង, លេខយោងជើងទំព័រលេខ៣៣។

## *ឧបសម្ព័ន្ធទី១២ និងទី១៣*

36. ឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធទី១២ នង១៣ មិនទាន់ត្រូវបានដាក់ឲ្យធ្វើការដេញដោលតទល់គ្នានៅឡើយ ហើយនីតិវិធីដាច់ដោយឡែកៗពីគ្នាត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យធ្វើការជំទាស់ទៅនឹងឯកសារទាំងនេះ[87]។ អាស្រ័យហេតុនេះ ឯកសារទាំងនេះ គឺមិនមែនជាផ្នែកត្រឹមត្រូវសម្រាប់ធ្វើការពិចារណានៅពេលបច្ចុប្បន្ននេះទេ។ ហើយឯកសារដែលឃើញមាននៅក្រោមលេខចាប់ពី៤៤៥-៤៧៨ នៃឯកសារE246/1/1.2 របស់ក្រុមមេធាវីការពារក្ដី គឺត្រូវបានដកចេញពីការពិភាក្សាដេញដោលណាពេលបច្ចុប្បន្ននេះ។

## *iii. ការច្រានចោលនូវឯកសារ"ថ្មី"ចំនួន៣៦ ពីក្នុងបញ្ជីឯកសារ លេខE109/4 ឧបសម្ព័ន្ធទី១-៥*

37. ក្រុមមេធាវីការពារក្ដីមិនអាចធ្វើមិនដឹងមិនឮចំពោះការពិតដែលថា តាមរយៈសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ឯកសារលេខ E185 ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះបន្ទាប់ពីសវនាការដែលបានធ្វើឡើងនៅចន្លោះរវាងថ្ងៃទី១៦ និង១៩ ខែមករា ឆ្នាំ២០១២ ស្ដីពីឯកសារទាំងអស់របស់កសព ដែលមាននៅក្នុងបញ្ជីដែលបានពិនិត្យឡើងវិញរួច ក្នុងឧបសម្ព័ន្ធពីទី១ ដល់ទី៥ (រួមទាំងឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង និងឯកសារ ថ្មី"ផង) ដែលបានទទួលយកនូវរាល់ឯកសារ"ថ្មី"ទាំងអស់ដែលរាយនៅក្នុងបញ្ជីនៅក្នុងឯកសារពីលេខA1-A5 លើកលែងតែឯកសារពីរចេញ (គឺមួយត្រូវបានចាត់ទុកថាមិនមានការជាប់ទាក់ទងគ្នា និងមួយទៀត ត្រូវបានយល់ព្រមតាមថាមិនអាចចូលទៅពិនិត្យមើលនៅក្នុងខ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ)[88]។ អាស្រ័យហេតុនេះ គឺឯកសារទាំងអស់ មិនអាចត្រូវបានទទួលនូវការទាស់តទៅទៀតនោះទេ ដោយសារការទទួលយក។

---

[87] សូមអានឯកសារលេខ **E96/7** សេចក្ដីសម្រេចលើសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២នៃវិធានផ្ទៃក្នុងទាក់ទងនឹងការទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារផ្សេងៗទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ មិថុនា ២០១២, កថាខណ្ឌទី៣ ។ ឯកសារលេខ **E208/3** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពី "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលទាក់ទងនឹងការជម្លៀសប្រជាជន ដំណាក់កាលទីមួយ និងទីពីរ (208 និង ឯកសារលេខ E208/2) និងចម្លើយតបរបស់ អៀង សារី (ឯកសារលេខ E208/1), ចុះថ្ងៃទី១៩ កក្កដា ២០១២, ត្រង់កថាខណ្ឌទី៣។

[88]ឯកសារលេខ **E185**, សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៩ មេសា ២០១២។ឯកសារលេខ **E185.2**, ឯកសារដែលបានលើកឡើងយោងនៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញាពីទី A1-A5, ជាភាសាអង់គ្លេសត្រង់លេខ ERN 00799038-39។ឯកសារដែលត្រូវ

38. ជាសរុបមកឯកសារ "ថ្មី"ចំនួន៣៥ ត្រូវបានទទួលយករួចហើយ ដោយសារតែមានការជាប់ទាក់ទងគ្នាផង និងអាចឲ្យជឿទុកចិត្តបានផង ដែលហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាត្រូវតែដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនូវ៖ ឯកសារចំនួន១៦ដែលមកពីឧបសម្ព័ន្ធទី១ (កំណត់ហេតុសួរចម្លើយជនជាប់ចោទ)[89], ឯកសារចំនួន១ដែលមកពីឧបសម្ព័ន្ធទី២ (ឯកសារចេញផ្សាយផ្សេងៗ និងសារាចរណែនាំនានារបស់ បកក)[90], ឯកសារចំនួន១១ដែលមកពីឧបសម្ព័ន្ធទី៤[91], និងឯកសារ៧ទៀតមកពីឧបសម្ព័ន្ធទី៥[92]។ ជាបន្ថែមពីលើឯកសារចំនួន៣៥ទាំងនោះ មានឯកសារ

បានយល់ឃើញថាមានការជាប់ទាក់ទងដោយសារតែជាប់ពាក់ព័ន្ធនឹង អៀង ធីរិទ្ធ គឺជារបាយការណ៍របស់បណ្តាញផ្សាយព័ត៌មានលេខចេញផ្សាយសម្រាប់ខែសីហា ឆ្នាំ១៩៨៦ [CGDK]។ ឯកសារដែលត្រូវបានយល់ព្រមតាមគឺជាឯកសារចេញផ្សាយរបស់រណៈសិរ្សរួបរួមជាតិកម្ពុជា FUNK ដែលមានចំណងជើងថា៖ "ព័ត៌មានស្តីពីប្រទេសកម្ពុជា Nouvelles du Cambodge លេខ៩៨៥", ដែលអាចរកមើលបានក្រោមឯកសារលេខ E109/4.5 ត្រង់លេខ១៧។ ឯកសារក្រោយនេះ នាពេលបច្ចុប្បន្ននេះមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងប្រព័ន្ធកុំព្យូទ័រ (សូមមើលឯកសារលេខ **E190/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីឯកសារថ្មីនិងបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធ, ចុះថ្ងៃទី១១ ឧសភា ២០១២) ហើយដែលក្រោយមកទៀតត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងក្នុងនាមជាភស្តុតាងដែលគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូងដែលនាំទៅរកការបង្ហាញឲ្យឃើញពីការពិត (ឯកសារលេខ **E190/2**, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការដាក់បញ្ចូលឯកសារថ្មីៗនៅក្នុងសំណុំរឿង, ចុះថ្ងៃទី៨ មិថុនា ២០១២)។

[89] សូមអាន ឯកសារលេខ **E185.2**,ឧបសម្ព័ន្ធ ខ – ឯកសារទាំងឡាយដែលត្រូវបានលើកឡើងយោងនៅក្នុងឧបសម្ព័ន្ធ A1-A5, របស់សហព្រះរាជអាជ្ញា,ឧបសម្ព័ន្ធ A1 ឯកសារថ្មី ត្រូវបានដាក់លេខសម្រាប់យោងឲ្យថា ឯកសារពីលេខ E3/704 ដល់លេខ E3/718 និងលេខ E3/830។ ត្រូវតែកត់សម្គាល់ថា ឯកសារលេខ១៥ ដែលរៀបចំធ្វើជាបញ្ជីដោយក្រុមមេធាវីការពារក្តីនៅក្នុងឯកសារលេខ E246/1/1.2 (ឧបសម្ពន្ធទី 1, លេខ១១៥) ត្រូវបានដាក់ចូលក្នុងសំណុំរឿងរួចហើយ ហើយកន្លងមកត្រូវបានទទួលយកដោយអង្គជំនុំជម្រះរួចហើយជាឯកសារលេខ D56 – Doc. 437 (ឯកសារលេខ E3/3802) ដូចដែលបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឯកសារលេខ E190, លេខយោងជើងទំព័រលេខ 45។ នៅចុងបញ្ចប់ ឯកសារលេខ ១៨ (ឧបសម្ព័ន្ធទី 1,លេខ ២៣៣) នៃតារាងដដែលត្រូវបានចាត់ទុកជាបណ្តោះអាសន្នថា មិនអាចទទួលយកបាន ដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានរកវាឃើញនៅក្នុង ឃ្លាំងផ្ទុកឯកសាររួមក្នុងប្រព័ន្ធកុំព្យូទ័រ។ ក្រោយពីសហព្រះរាជអាជ្ញាបានពន្យល់អំពីថាតើអាចរកវានៅកន្លែងណាទើបឃើញ នៅក្នុងប្រព័ន្ធ Zylab (ឯកសារលេខ E190/1, កថាខណ្ឌទី២), ទើបបន្ទាប់មកឯកសារនោះត្រូវបានអង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលទៅក្នុងសំណុំរឿងតាមរយៈដីកាសម្រេចរបស់ខ្លួន ឯកសារលេខ**E190/2**។ ក្នុងគ្រប់ករណីទាំងអស់ ក្រុមមេធាវីការពារក្តីមិនបានលើកឡើងនូវនូវការជំទាស់ណាមួយទាក់ទងនឹងឯកសារនេះ នៅក្នុងឯកសារលេខ E246/1/1.2 ឡើយ។

[90] ឯកសារលេខ **E185.2**, ឧបសម្ព័ន្ធខ – ឯកសារដែលបានលើកឡើងនៅក្នុឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា, ឧបសម្ព័ន្ធA2 ឯកសារថ្មី ឯកសារលេខ E3/791។

[91] ឯកសារលេខ **E185.2**, ឧបសម្ព័ន្ធខ –ឧបសម្ព័ន្ធ A4 ឯកសារថ្មី ឯកសារពីលេខ E3/1228 ដល់ឯកសារលេខ E3/1237 និងលេខ E3/1582។

[92] ឯកសារលេខ **E185.2**, ឧបសម្ព័ន្ធខ –ឧបសម្ព័ន្ធ A5 ឯកសារថ្មី ឯកសារពីលេខ E3/1485 ដល់លេខ E3/1491 ។ បន្ថែមពីលើឯកសារទាំង ៣៥, ឯកសារលេខ E3/30 បានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។

មួយផ្សេងទៀតធ្លាប់ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[93]។ ឯកសារនីមួយៗក្នុងចំណោមឯកសារទាំងនោះ ត្រូវបានដាក់លេខយោងថា E3 ជាប្រការមួយដែលធ្វើឲ្យក្រុមមេធាវីការពារក្តីមិនបានគិតឃើញថា ឯកសារទាំងនោះត្រូវបានអង្គជំនុំជម្រះទទួលយករួចហើយនោះទេ "បានសង្កេតឃើញ និងសំដែងការសោកស្តាយ"[94]។

39. ជាងនេះទៅទៀត មេធាវីការពារក្តីបានលើកឡើងនូវការជំទាស់ទាក់ទងទៅនឹងឯកសារ "ថ្មី" នីមួយៗទាំង ១៦ ឯកសារនៃឧបសម្ព័ន្ធទី១ នៅក្នុងខ្ទង់ "សេចក្តីសង្កេត" នៃតារាង E246/1/1.2 របស់ខ្លួន។ ដោយហេតុថាសេចក្តីសម្រេចទទួលយកឯកសារទាំងនោះ ត្រូវបានចេញរួចហើយ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ការជំទាស់ទាំងនោះត្រូវតែបានចាត់ទុកថា លែងចាំបាច់ទៀតហើយ។ លើសពីនេះ អំណះអំណាងដែលបានធ្វើឡើងនៅក្នុងកថាខណ្ឌ ២៦ នៃការដាក់ឯកសាររបស់មេធាវីការពារក្តីទាក់ទងទៅនឹងឯកសារ E3/705 និង E3/717 គឺមិនមានមានការទាក់ទងគ្នាទេ ដោយហេតុថាឯកសារដែលបានរៀបរាប់ទាំងនោះ គឺជាឯកសារនៃឧបសម្ព័ន្ធទី១ ដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះរួចហើយ។ មេធាវីការពារក្តីបានអះអាងថា ពួកខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការជំទាស់ទៅនឹងឯកសារ "ថ្មី" ទាំងអស់ដទៃទៀត ដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ក២-ក៥[95]។

## iv. *<u>មេធាវីការពារក្តីបានធ្វើការជំទាស់យ៉ាងមានប្រសិទ្ធិភាពតែទៅលើឯកសារចំនួន ១២ ដែលមាននៅក្នុងតារាង E246/1/1.2 ប៉ុណ្ណោះ</u>*

[93] ឯកសារលេខ **E3/30**, សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានចំណងជើងថា "ក្រិត្យច្បាប់របស់សីហនុ ចុះថ្ងៃទី១៥ វិច្ឆិកា ៧៤ របស់ RGUNC" និង "ឈ្មោះថ្មីរបស់គណៈរដ្ឋមន្ត្រីនានាដល់គណៈរដ្ឋមន្ត្រីនៃ RGUNC ថ្មីរបស់សីហនុ" (Cambodian Information Agency)។

[94] ឯកសារលេខ **E246/1/1.2**, ការជំទាស់របស់ ខៀវ សំផន ទៅនឹងភាពអាចទទួលយកបាននៃឯកសារថ្មី, ត្រង់កថាខណ្ឌទី៥ដែល បានថ្លែងថា៖ "ប៉ុន្តែក្រុមមេធាវីការពាររបស់ ខៀវ សំផន បានសង្កេត និងបានសម្តែងការសោកស្តាយចំពោះប្រការដែលទោះបីជាមិនបានបើកធ្វើកិច្ចដំណើរការនីតិវិធីតទល់គ្នាលើឯកសារនោះក្តីក៏ឯកសារមួយចំនួនត្រូវបានដាក់លេខយោងជាលេខ E3 ហើយដែរ"។

[95] ឯកសារទាំងនោះ គឺមានដូចតទៅ៖ (១) <u>ឧបសម្ព័ន្ធ ២៖</u> លេខ ៨០ (E3/791) ចុះបញ្ជីជាលេខ ៣៥ នៅក្នុង E256/1/1.2។ (២) <u>ឧបសម្ព័ន្ធ ៤៖</u> លេខ ៩ (E3/1235), 32 (E3/1233), 66 (E3/1230), 388 (E3/1582), 73 (E3/1237), 75 (E3/1234), 79 (E3/1231), 137 (E3/1229), 217 (E3/1232), 223 (E3/1228), 225 (E3/1236), ចុះបញ្ជីលេខ ៥២-៦២ នៅក្នុង E256/1/1.2 ។ (៣) <u>ឧបសម្ព័ន្ធ ៥៖</u> លេខ ៧៣ (E3/1485), 245 (E3/1486), 123 (E3/1487), 278 (E3/1491), 283 (E3/1488), 355 (E3/1489), 357 (E3/1490), 14 (E3/30, បានដាក់ពីមុន នៅចំពោះមុខអង្គជំនុំជម្រះ)។

40. សហព្រះរាជអាជ្ញាសង្កេតឃើញថា ជាការបន្ថែមទៅនឹងឯកសារចំនួន ៩៩ ដែលបានយោងនៅខាងលើ ចាប់ពី (i) ដល់ (iii) ដែលមិនអាចទទួលយកការជំទាស់បានទៀតហើយ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី មេធាវីការពារក្តីបានជ្រើសរើសមិនជំទាស់ទៅនឹងឯកសារចំនួន ៣៦៧ ទេ ដោយបានអះអាងថា មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើដូច្នោះទេ។ បន្ថែមលើនេះ មេធាវីការពារក្តីមិនបានប្រឆាំងទៅនឹងការប្រើប្រាស់ឯកសារចំនួន ២[96] និងបានពោលថាខ្សែវីឌីអូមួយត្រូវបានជជែកគ្នាកាលពីខែមករា ឆ្នាំ២០១៣[97]។

41. ដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីគឺមានពេលវេលាហួសពីគ្រប់គ្រាន់ ដើម្បីរៀបចំការជំទាស់ណាមួយទៅនឹងឯកសារចំនួន ៣៦៧ ទាំងនោះ។ ឯកសារទាំងនេះត្រូវបានកំណត់អត្តសញ្ញាណតាំងពីដើមខែមេសា ឆ្នាំ២០១១មកម្ល៉េះ ហើយត្រូវបានបញ្ជាក់បន្ថែមទៀតកាលពីខែកក្កដា ឆ្នាំ២០១១។ ទោះបីជាវាមិនមាននៅក្នុងសំណុំរឿងក៏ដោយ ក៏គ្រប់ភាគីទាំងអស់ និងអង្គជំនុំជម្រះសាលាដំបូង អាចបើកមើលឯកសារទាំងនោះនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD) បានដែរ ដូចសហព្រះរាជអាជ្ញាបានកត់សម្គាល់ចំពោះមេធាវីការពារក្តី នៅខែវិច្ឆិកា ឆ្នាំ២០១១[98]។ រឿងនេះត្រូវបានបញ្ជាក់ដោយការដាក់ឯកសារពីសំណាក់សហព្រះរាជអាជ្ញា[99] និងអង្គជំនុំជម្រះសាលាដំបូង[100] ព្រមទាំង មេធាវីការពារក្តី អៀង សារី ផងដែរ[101]។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា មេធាវីការពារក្តី អៀង សារី បានដាក់ការជំទាស់ទៅនឹងឯកសារ "ថ្មី" ទាំងអស់ដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធចាប់ពី ក១ ដល់ ក៦ និងចាប់ពី ក៨ ដល់ ក២០ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ព្រមទាំងមិនដែលបានពោលពីការលំបាកអ្វីទាល់តែសោះ នៅក្នុងការបើកមើលឯកសារទាំងនោះនៅក្នុង SMD [102]។

---

[96] **E246/1/1.2**, លេខ ២៥ (ឧបសម្ព័ន្ធ ១៩, លេខ ៨៩ នៃ E109/4) និង ២៧ (ឧបសម្ព័ន្ធ ១៩, លេខ ៩០)។

[97] **E246/1/1.2**, លេខ ៤៨១ (ឧបសម្ព័ន្ធ ១៦, លេខ ២៥៦ នៃ E109/4 និង **E223/2.2.1** លេខ ៧)។

[98] **E131/19** ចម្លើយតបរួមរបស់ ក.ស.ព ទៅនឹងការជំទាស់លើឯកសារ សម្រាប់សវនាការដំណាក់កាលទី១ , ១ ធ្នូ ២០១១, កថាខណ្ឌ ៥១។

[99] **E131/19** ចម្លើយតបរួមរបស់ ក.ស.ព, ១ ធ្នូ ២០១១, កថាខណ្ឌ ៥១។ **E158**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាម វិធាន ៩២ ទាក់ទិននឹងសូចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង, ២៣ ធ្នូ ២០១១, រួមបញ្ចូលកំណត់សម្គាល់ជើងទំព័រលេខ ១៤៨, ១៥៥, ១៨១, ៣០៩, ៣២៩ និង ៤១៥។

[100] **E190**, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, ៣០ មេសា ២០១២, កថាខណ្ឌ ២៧, កំណត់សម្គាល់ជើងទំព័រលេខ ៣៩។

[101] **E131/1/10**, ការជំទាស់របស់លោក អៀង សារី, ៥ មករា ២០១២។ សំណើរបស់ អៀង សារី ស្នើសុំការបញ្ជាក់ពាក់ព័ន្ធនឹងការជំទាស់ទៅនឹងឯកសារថ្មី, អ៊ីមែលផ្ញើកាលពីថ្ងៃទី ៦ កុម្ភៈ ២០១៣, ដោយបានថ្លែងនៅក្នុងកថាខណ្ឌ ២ ថា៖ "[...] យើងបានជំទាស់ទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ ក២១ ជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ៥ មករា ២០១២ និងបន្ទាប់មក ជាថ្មីម្តងទៀត នៅក្នុងអំឡុងពេលនៃការដេញដោលផ្ទាល់មាត់ នៅថ្ងៃទី ១៦-១៩ មករា ២០១២ និង ១២-១៥ មីនា ២០១២"។

[102] **E131/1/10**, ការជំទាស់របស់លោក អៀង សារី, ៥ មករា ២០១២។

42. សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា មានតែការជំទាស់ចំនួន១២ ដែលបានដាក់ ដោយមេធាវីការពារក្តីប៉ុណ្ណោះ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឯកសារទាំងនោះនៅមិនទាន់បានជជែកគ្នានៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ[103]។ ឯកសារ "ថ្មី" ទាំង ១២ នេះមានផ្ទុកទៅដោយរបាយការណ៍វិភាគចំនួន០៧, សៀវភៅចំនួន០៤ ហើយនិងរបាយការណ៍សារព័ត៌មានអន្តរជាតិចំនួន០១ (ដែលមាននៅក្នុងបញ្ជីដែលបានពិនិត្យឡើងវិញរបស់ ក.ស.ព, ឧបសម្ព័ន្ធ ក១៨ និង ក១៩)។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ឯកសារទាំងនោះមានបង្ហាញពីទ្រង់ទ្រាយដូចគ្នាបេះបិទទៅនឹងឯកសារជាច្រើនដែលត្រូវបានទទួលយកនៅក្នុងសេចក្តីសម្រេច E185/1 របស់អង្គជំនុំជម្រះ គឺមានរបាយការណ៍សារព័ត៌មានអន្តរជាតិចំនួនជាង៣០០ និងអត្ថបទស្រាវជ្រាវរបាយការណ៍វិភាគ និងសៀវភៅមានចំនួនជាង២០០។ អង្គជំនុំជម្រះក៏បានថ្លែងផងដែរថា សម្ភារៈឯកសារ បែបដូចជា របាយការណ៍វិភាគ សៀវភៅ និងអត្ថបទសារព័ត៌មាន អាចនឹងមានការទាក់ទងគ្នា ហើយនិងមិនត្រូវដាក់ឲ្យនៅក្រៅពីប្រភេទណាមួយនោះឡើយ[104]។ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសង្កេតយ៉ាងជាក់លាក់ ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃឯកសារចំនួន១២ទាំងនេះ នៅក្នុងតារាងមួយដែលភ្ជាប់ទៅនឹងចម្លើយតបនេះ (ឧបសម្ព័ន្ធ ក)។

43. ទាក់ទងទៅនឹងសេចក្តីសង្កេត ដែលបានធ្វើឡើងដោយមេធាវីការពារក្តីនៅក្នុងកថាខណ្ឌចាប់ពី ២៦ , ២៧ និង៣០ នៃការជំទាស់របស់ខ្លួននោះ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថា ភាគច្រើននៃការជំទាស់ទាំងនោះ គឺមានលក្ខណៈជាទូទៅ មិនមានភាពជាក់លាក់ និងមិនមានធ្វើការកំណត់អត្តសញ្ញាណពីចរិតលក្ខណៈនានាដែលនឹងធ្វើឲ្យឯកសារទាំងនោះទៅជា មិនអាចទុកចិត្តបាន ឬមិនអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះ (កថាខណ្ឌ ២៦-២៧, ៣០)។ នៅក្នុងកថាខណ្ឌ ២៧ មេធាវីការពារក្តី បានបង្ហាញពីសេចក្តីសង្កេតជាទូទៅ ទាក់ទងទៅនឹងរូបថតនានា ដែលមិនមាន

---

[103] ឯកសារទាំងនោះ គឺមានដូចតទៅ៖ (១) <u>ឧបសម្ព័ន្ធ ១៨៖</u> លេខ ១៤៦ (E190.1.327, ហើយត្រូវបានរកឃើញផងដែរ នៅត្រង់លេខ ៩៧ នៅក្នុងតារាងរបស់ ខៀវ សំផន ឯកសារ E246/1/1.2); (២) <u>ឧបសម្ព័ន្ធ ១៩៖</u> លេខ ២០ (E190.1.391, លេខ ១៩ នៅក្នុងឯកសារ E246/1/1.2), លេខ ២១ (E190.1.392, លេខ ២០ នៅក្នុងឯកសារ E246/1/1.2), លេខ ៣៨ (E190.1.393, លេខ ២៣ នៅក្នុងឯកសារ E246/1/1.2), លេខ ៥១ (E190.1.394, លេខ ២៤ នៅក្នុងឯកសារ E246/1/1.2), លេខ ១៣៧ (E190.1.399, លេខ ២៦ នៅក្នុងឯកសារ E246/1/1.2), លេខ ៧៦ (E190.1.396, លេខ ២៨ នៅក្នុងឯកសារ E246/1/1.2), លេខ ៦៩ (E190.1.395, លេខ ២៩ នៅក្នុងឯកសារ E246/1/1.2), លេខ ២៣៤ (E190.1.403, លេខ ៣០ នៅក្នុងឯកសារ E246/1/1.2), លេខ ២៣២ (E190.1.402, លេខ ៣១ នៅក្នុងឯកសារ E246/1/1.2), លេខ ២២៥ (E190.1.400, លេខ ៣២ នៅក្នុងឯកសារ E246/1/1.2), លេខ ២២៧ (E190.1.401, លេខ ៣៣ នៅក្នុងឯកសារ E246/1/1.2)។

[104] **E185**, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, ៩ មេសា ២០១២, កថាខណ្ឌ ២១(៥)។

កាលបរិច្ឆេទ ឬដែលគេមិនបានកំណត់អត្តសញ្ញាណម្ចាស់នៅក្នុងរូបថត។ ការកត់សម្គាល់នេះ គឺមានលក្ខណៈទូលំទូលាយណាស់ ហើយផ្ទុយទៅនឹងអង្គហេតុពិតដែលថា មេធាវីការពារក្តីបានធ្វើការអះអាងថា ខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការពិនិត្យឡើងវិញពីភាពអាចទទួលយកបាននៃរូបថតណាមួយក៏ដោយដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ១៥ នៃបញ្ជីឯកសាររបស់ ក.ស.ព។ បន្ថែមលើនេះ ដោយផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្តី ដែលមាននៅក្នុងកថាខណ្ឌ ២៧ នៅក្នុងចំណោមឯកសារចំនួន១២ ដែលបានជំទាស់នោះ គឺមិនមានឯកសារណាមួយដែលមិនមានភាសាដើមជាភាសាខ្មែរ នោះឡើយ។

## IV. សេចក្តីសន្និដ្ឋាន

44. អាស្រ័យដោយមូលហេតុខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់ អង្គជំនុំជម្រះសាលាដំបូងឲ្យ៖

**ក. សម្រេចថា** មេធាវីការពារក្តីមានឱកាសយ៉ាងពេញលេញ ដើម្បីធ្វើការជំទាស់ទៅនឹងឯកសារទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ១-១១ និង ១៤-២០ នៃបញ្ជីដែលបានពិនិត្យឡើងវិញរបស់សហព្រះរាជអាជ្ញា ហើយដូច្នេះ បដិសេធការជំទាស់របស់មេធាវីការពារក្តីថាមិនអាចទទួលយកបាន ឬ

**ខ. បែងចែក** ការជំទាស់របស់មេធាវីការពារក្តី ដូចដែលបានបញ្ជាក់ខាងលើ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |